ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៥/២៤-កូម៉ូ អឹកែរីល ឯ.ក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ុក រី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន កូម៉ូ អឹកែរីល ឯ.ក**
អាសយដ្ឋាន ៖ ភូមិអំពិល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩៦ ៣៩៤ ៨៩ ៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ ៖

| | | |
|---|---|---|
| ១- លោក | គ ម ស | ប្រធានរដ្ឋបាល |
| ២- លោក | ឆ ម ល | អនុប្រធានរដ្ឋបាល |
| ៣- កញ្ញា | ស ល ដ | អនុប្រធានរដ្ឋបាល |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន កូម៉ូ អឹកែរីល ឯ.ក**
អាសយដ្ឋាន ៖ ភូមិអំពិល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៨៧ ៣០០ ០៦៣/០៨៨ ៥០២ ៥៥ ៩១ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

| | | |
|---|---|---|
| ១- លោក | ខផន | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ (KUFWS) |
| ២- លោក | ជរម | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ (KUFWS) |
| ៣- លោក | មម | មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ (KUFWS) |

៤- លោកស្រី ឈឹម ប្រធានសហជីព (មូលដ្ឋាន)

៥- លោកស្រី វថ អនុប្រធានសហជីព (មូលដ្ឋាន)

៦- លោកស្រី សសរ ហេរញ្ញិកសហជីព (មូលដ្ឋាន)

៧- លោក ផវណ សកម្មជន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- តំណាងកម្មករនិយោជិតស្នើសុំឱ្យនិយោជក នៅពេលមានតម្រូវការឱ្យកម្មករកម្មការិនីធ្វើការបន្ថែមម៉ោងដល់ម៉ោង២០ សុំអនុញ្ញាតឱ្យកម្មករកម្មការិនីបានចេញសម្រាកចំនួន ១៥នាទី ដើម្បីហូបអាហារសម្រន់ផង។ ដោយឡែក នាយកក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនពុំអនុញ្ញាតឱ្យកម្មករនិយោជិតឈប់សម្រាកចំនួន ១៥នាទី ដើម្បីហូបអាហារសម្រន់ទេ។

២- តំណាងកម្មករនិយោជិតស្នើសុំឱ្យនិយោជកអនុញ្ញាតឱ្យកម្មករកម្មការិនីបានប្រើប្រាស់ការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ថ្ងៃទី១១, ១២ និង១៧ ខែមេសា ឆ្នាំ២០២៤ ដើម្បីឈប់ភ្ជាប់ជាមួយថ្ងៃបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរខាងមុខ។ ដោយឡែក នាយកក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅលើកិច្ចព្រមព្រៀងរវាងនាយកក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ស្តីពីការដោះដូរថ្ងៃឈប់សម្រាកនាពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរដែលប្រព្រឹត្តទៅនាខែមេសា ឆ្នាំ២០២៤ ចុះថ្ងៃទី២៧ កុម្ភៈ ឆ្នាំ២០២៤ (ឯកសារជូនភ្ជាប់មកជាមួយ)។

៣- តំណាងកម្មករនិយោជិតស្នើសុំឱ្យនិយោជកផ្តល់អាហារថ្ងៃត្រង់មួយពេល ឬអាចផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ជូនកម្មករកម្មការិនី ដោយបើកជូនជារៀងរាល់ថ្ងៃ។ ដោយឡែក នាយកក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តតាមគោលការណ៍ចាស់ផ្តល់ជាប្រាក់ចំនួន ១៥០០រៀល ជូនកម្មករនិយោជិត និងបើករៀងរាល់មួយសប្តាហ៍ម្តង។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.វ. ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិន[illegible]ឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន កូម៉ូ អ៊ី[illegible] ឯ.ក លេខ ២៦[illegible] ក.ប/អក/វក ចុះថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១៤កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្ដឹងរបស់ភាគីកម្មករនិយោជិតនៃក្រុមហ៊ុន កូម៉ូ អ៊ីកែរីល ឯ.ក ស្ដីពីការទាមទារសុំឱ្យក្រុមហ៊ុនកែលម្អលក្ខខណ្ឌការងារចំនួន ១៤ ចំណុច ឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្ដឹងនេះរួចមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះទៅតាមនីតិវិធីច្បាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១១ចំណុច លើការទាមទារចំនួន ១៤ចំណុច។ ចំណុចមិនសះជាចំនួន ៣ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន កូម៉ូ អ៊ីកែរីល ឯ.ក លេខ ២៦០ ក.ប/អក/វក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៣ចំណុចនេះ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ៨ និង ៣០ នាទីព្រឹក។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមស្វែងរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៣ចំណុចនេះ និងបានផ្សះផ្សាចំណុចវិវាទនេះបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងគ្នាលើចំណុចវិវាទទី២។ ភាគីកម្មករនិយោជិតបានដកចំណុចវិវាទទី១ ចេញពីសំណុំរឿងនេះ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាលើចំណុចវិវាទដែលនៅសល់ គឺចំណុចវិវាទទី៣។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច។

កាលបរិច្ឆេទនៃការចេញសេចក្ដីបង្គាប់អាជ្ញាកណ្ដាល នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទដែលនៅសល់ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០២៤ របស់លោក ZWL ជាម្ចាស់ ឬនាយកសហគ្រាស កូម៉ូ អ៊ីកែរីល ឯ.ក គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសំណើសុំផ្ទេរសិទ្ធិជូនលោក តមស ជាប្រធានផ្នែករដ្ឋបាលឈ្មោះ សលដ

និង អ្នកនាង ឆមល ជាអនុប្រធានរដ្ឋបាល ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន ព្រមទាំងមានសិទ្ធិសម្រេចរាល់កិច្ចព្រមព្រៀងផ្សេងៗផងដែរ ដើម្បីទំនាក់ទំនងជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងករណីវិវាទរួមនៅសហគ្រាស កូម៉ូ អ៊ីតែរឹល ឯ.ក ក្នុងសំណុំរឿងលេខ ០០៥/២៤។

២- លិខិតចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ របស់សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក សូមគោរពចូលមក លោកនាយកក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ស្តីពីសំណើសុំជួបពិភាក្សាដោះស្រាយសម្របសម្រួល នូវលក្ខខណ្ឌការងាររួមរបស់កម្មករនិយោជិតចំនួន ១៤ចំណុច ដែលបានពឹងពាក់មកសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ដើម្បីជួយដោះស្រាយសម្របសម្រួលជាមួយភាគីក្រុមហ៊ុន និងស្ថាប័នពាក់ព័ន្ធ ដែលជាសំណូមពររបស់កម្មករនិយោជិត។

៣- លិខិតពឹងពាក់ និងជួយអមប្រឹក្សាយោបល់ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់ថ្នាក់ដឹកនាំសហជីពស្មារតីកម្មករខ្មែរ និងប្រតិភូចរចាក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក សូមគោរពចូលមក លោកប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ស្តីពីសំណើសុំពឹងពាក់ និងជួយអមប្រឹក្សាយោបល់ពីលោកប្រធាន ក្នុងការជួយសម្របសម្រួលដោះស្រាយនូវវិវាទការងាររួមចំនួន ១៤ចំណុច ជាមួយភាគីក្រុមហ៊ុន ក្រសួងការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល តុលាការ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ។

៤- លិខិតចាត់តាំងប្រតិភូចរចាដោះស្រាយលក្ខខណ្ឌការងាររួមនៅក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ របស់កម្មករនិយោជិតនៃក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក សូមគោរពចូលមក លោកនាយកក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ស្តីពីសំណើសុំចាត់ប្រតិភូចរចា ដើម្បីដោះស្រាយវិវាទការងាររួមចំនួន ១៤ចំណុច របស់យើងខ្ញុំទាំងអស់គ្នានៅក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៤:០០ នាទី ល្ងាច។

៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក លេខ MOC-០០០១១០៦៩ ពណ.ចបព ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២២។

៦- លក្ខន្តិកៈរបស់ក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក បានតម្កល់ទុកលេខ ១០០០១១៧៣៣៨ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៧- ឯកសារគម្រោងសិក្សាសមិទ្ធិលទ្ធភាព ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១។

៨- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក បានចុះទិដ្ឋាការលេខ E1IR20220682 អធក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២ ដោយនាយកដ្ឋានអធិការកិច្ចការងារ។

៩- សេចក្តីប្រកាសជូនដំណឹងរបស់ក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ចុះថ្ងៃទី២ ខែ[illegible]សភា ឆ្នាំ២០[illegible]។

១០-ឯកសារកិច្ចព្រមព្រៀងរវាងនាយកក្រុមហ៊ុន កូម៉ូ អ៊ីតែរឹល ឯ.ក ជាមួយតំណាងកម្មករ សហជីព និងប្រធានក្រុម គ្រប់ក្រុម គ្រប់ផ្នែក ក្រុមហ៊ុនផ្តល់ជូនប្រាក់ធ្វើដំណើរ ១ថ្ងៃ ([illegible]) ក្នុងថ្ងៃបុណ្យចូលឆ្នាំប្រពៃណីខ្មែរស្ថិតនៅក្នុងខែមេសា ឆ្នាំ២០២៤។

១១- កិច្ចព្រមព្រៀង និងសេចក្តីប្រកាស ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក ស្តីអំពីការដោះដូរថ្ងៃឈប់សម្រាកនាពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ដែលប្រព្រឹត្តទៅនាខែមេសា ឆ្នាំ២០២៤។

១២- បញ្ជីឈ្មោះអ្នកចូលរួមប្រជុំថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤។

១៣- ស្នាមមេដៃ តំណាងកម្មករ-សហជីព ស្តីពីការព្រមព្រៀង ឈប់សម្រាកប្រចាំឆ្នាំ និងការដោះដូរថ្ងៃឈប់សម្រាកនាពិធីបុណ្យ ចូលឆ្នាំប្រពៃណីជាតិខ្មែរ ដែលប្រព្រឹត្តទៅនាខែមេសា ឆ្នាំ២០២៤។

១៤- សេចក្តីប្រកាសជូនដំណឹងរបស់ក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៤។

១៥- ឯកសារបញ្ជីបើកប្រាក់ឈ្នួលប្រចាំខែមីនា ឆ្នាំ២០២៤ របស់ក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ របស់សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក សូមគោរពចូលមក លោកនាយកក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក ស្តីពីសំណើសុំជួបពិភាក្សាដោះ-ស្រាយសម្របសម្រួល នូវលក្ខខណ្ឌការងាររួមរបស់កម្មករនិយោជិតចំនួន ១៤ចំណុច ដែលបានពឹងពាក់មកសហជីពស្មារតីកម្មករខ្មែរប្រចាំក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក ដើម្បីជួយដោះស្រាយសម្របសម្រួលជាមួយភាគីក្រុមហ៊ុន និងស្ថាប័នពាក់ព័ន្ធ ដែលជាសំណូមពររបស់កម្មករនិយោជិត។

២- លិខិតពឹងពាក់ និងជួយអមប្រឹក្សាយោបល់ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ របស់ថ្នាក់ដឹកនាំសហ-ជីពស្មារតីកម្មករខ្មែរ និងប្រតិភូចរចាក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក សូមគោរពចូលមក លោកប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ស្តីពីសំណើសុំពឹងពាក់ និងជួយអមប្រឹក្សាយោបល់ពី លោកប្រធាន ក្នុងការជួយសម្របសម្រួលដោះស្រាយនូវវិវាទការងាររួមចំនួន ១៤ចំណុច ជាមួយភាគីក្រុមហ៊ុន ក្រសួងការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាល តុលាការ អាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ។

៣- លិខិតចាត់តាំងប្រតិភូចរចាដោះស្រាយលក្ខខណ្ឌការងាររួមនៅក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ របស់កម្មករនិយោជិតនៃក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក សូមគោរពចូលមក លោកនាយកក្រុមហ៊ុន៖ កូម៉ូ អីកែវឺល ឯ.ក ស្តីពីសំណើសុំចាត់ប្រតិភូចរចា ដើម្បីដោះស្រាយវិវាទការងាររួមចំនួន ១៤ចំណុច របស់យើងខ្ញុំទាំងអស់គ្នានៅក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៤: ០០ នាទី ល្ងាច។

៤- ឯកសារកិច្ចព្រមព្រៀង ស្តីពីការសម្រុះសម្រួលករណីវិវាទការងាររវាងកម្មករនិយោជិត និងក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក កាលពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ១៥ និង ០០ នាទីល្ងាច មានការប្រជុំស្តីពីការសម្រុះសម្រួលករណីវិវាទនៅក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក មានទីតាំងស្ថិតនៅភូមិ-អំពិល សង្កាត់កំបូល ខណ្ឌកំបូល រាជធានីភ្នំពេញ។

៥- បញ្ជីឈ្មោះអ្នកដែលបានចូលរួមប្រជុំស្តីពីការព្រមព្រៀងចុះហត្ថលេខា រវាងក្រុមហ៊ុន និងសហជីព ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣។

៦- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន កូម៉ូ អីកែវឺល ឯ.ក លេខ ៤៩៤/២២ ក.ប/រ.ប.វ.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២។

៧- លិខិតលេខ ២៣៧/២២ ក.ប/វ.ក ចុះថ្ងៃអង្គារ ១២រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅនាយកដ្ឋានវិវាទការងារ និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៨- លិខិតចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៤ របស់សហជីពស្មារតីកម្មករខ្មែរក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក សូមគោរពចូលមក លោកនាយកដ្ឋានវិវាទការងារ ស្តីពីការស្នើសុំអន្តរាគមដោះស្រាយសម្របសម្រួល នូវលក្ខខណ្ឌការងាររួមរបស់កម្មករនិយោជិតចំនួន ១៤ចំណុច ដែលក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក មិនបានជួបពិភាក្សាដោះស្រាយវិវាទការងាររបស់កម្មករនិយោជិតទៅតាមកាលកំណត់នៃលិខិតស្នើសុំ។

៩- លិខិតផ្ទេរសិទ្ធិ ក្នុងការជួយអមប្រឹក្សាយោបល់លេខ ០០៤/២៤ ស.ស.ស.ក.ខ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤ របស់លោក មស ជាប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ សូមផ្ទេរសិទ្ធិ ក្នុងការជួយអមប្រឹក្សាយោបល់ឱ្យ លោក សសខ តួនាទីជាអគ្គលេខាធិការ លោក តួនាទីជាមន្ត្រីសម្របសម្រួល និងលោក ជវម តួនាទីជាមន្ត្រីសម្របសម្រួល នៃសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ដើម្បីមានសិទ្ធិគ្រប់គ្រាន់ក្នុងកិច្ចទំនាក់ទំនងជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរ និងស្ថាប័នគ្រប់ជាន់ថ្នាក់ និងមានសិទ្ធិសម្រេចគ្រប់កិច្ចការដែលពាក់ព័ន្ធ នឹងដោះស្រាយករណីវិវាទការងាររួម ជាមួយភាគីក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក។

១០- លិខិតអញ្ជើញលេខ ៤១៤ ក.ប/អ.ក/វ.ក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤ របស់នាយកដ្ឋានវិវាទការងារ អញ្ជើញតំណាងកម្មករនិយោជិត លោកស្រី ឈម , លោកស្រី វច , លោក សចរ , លោក ជសរ លោក ផវណ , លោក សប , លោក ឆឆវ , លោក សស ដើម្បីចូលរួមផ្សះផ្សាពាក់ព័ន្ធទៅនឹងបណ្តឹងរបស់តំណាងកម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនដោះស្រាយនូវចំណុចទាមទារចំនួន ១៤ចំណុច ឱ្យបានល្អប្រសើរ។

១១- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក របស់នាយកដ្ឋានវិវាទការងារ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤។

១២- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានតំណាងកម្មករនិយោជិត លោកស្រី ឈម , លោកស្រី វច , លោក សចរ , លោក ជសរ , លោក ផវណ , លោក សប , លោក ឆឆវ , លោក លោក សស , លោក ជវម ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ នៅនាយកដ្ឋានវិវាទកាងារ។

១៣- ឯកសារស្នាមមេដៃរបស់កម្មករនិយោជិតនៃក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន កូម៉ូ អ៊ីកែរឹល ឯ.ក លេខ ២៦០ ក.ប/អក/វក ចុះថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន កូម៉ូ អីកែរឹល ឯ.ក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន កូម៉ូ អីកែរឹល ឯ.ក លេខ ០០១/២៤ កប/អក/កវក២ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០២៣ កប/អក/វក/លកអ ចុះថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០២៤ កប/អក/វក/លកអ ចុះថ្ងៃព្រហស្បតិ៍ ៣កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៤។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន កូម៉ូ អីកែរឹល ឯ.ក មានសកម្មភាពចម្បងផ្នែក កាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ១៦០៥នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន កូម៉ូ អីកែរឹល ឯ.ក លេខ ២៦០ ក.ប/អក/វក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤)*
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមលេខ ០០១/២៤ ក.ប/អក/វក/កវក២ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៤ ដែលមានកម្មករនិយោជិតចំនួន ៥នាក់ រួមមាន ៖ ១. ឈម , ២. វថ , ៣. សសរ , ៤. ផវណ ;, និង ៥. មជ ។

**ចំណុចវិវាទទី៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់អាហារថ្ងៃត្រង់មួយពេល ឬអាចផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ជូនកម្មករនិយោជិត ដោយបើកជារៀងរាល់ថ្ងៃ**

- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - ការអនុវត្តនៅក្នុងក្រុមហ៊ុនចាប់ពីពេលបើកដំណើរការ រហូតដល់បច្ចុប្បន្ន និយោជកផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ជូនកម្មករនិយោជិតចំនួន ១៥០០រៀល ក្នុងមួយថ្ងៃ និងបើកជូនកម្មករនិយោជិតរៀងរាល់មួយសប្តាហ៍ម្តងនៅថ្ងៃសៅរ៍។
  - ក្រៅពីការអនុវត្តរបស់និយោជកខាងលើ មិនមានបទប្បញ្ញត្តិណាកំណត់ឱ្យផ្តល់ប្រាក់បាយថ្ងៃត្រង់ចំនួន ៤០០០រៀល ដោយបើកជារៀងរាល់ថ្ងៃជូនកម្មករនិយោជិតនោះទេ។
  - នៅក្នុងក្រុមហ៊ុនមិនមានសហជីពដែលមានភាពជាតំណាងបំផុតនោះទេ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖

    ០ និយោជកផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ចំនួន ១៥០០រៀល ក្នុងមួយថ្ងៃ គឺមានចំនួនតិចពេក មិនគ្រប់គ្រាន់សម្រាប់ថ្លៃបាយថ្ងៃត្រង់របស់កម្មករនិយោជិតនោះទេ។
    ០ម្យ៉ាងទៀត កម្មករនិយោជិតត្រូវការប្រាក់ថ្លៃបាយថ្ងៃត្រង់សម្រាប់ទិញបាយហូបជារៀងរាល់ថ្ងៃ។
    ០ ចំពោះប្រាក់ឈ្នួលដែលកម្មករនិយោជិតទទួលបានក្នុងមួយខែៗ កម្មករនិយោជិតត្រូវបង់ធនាគារ ចំណាយលើម្ហូបអាហារពេលព្រឹក និងពេលយប់ ហេតុនេះ កម្មករនិយោជិតត្រូវការប្រាក់ថ្លៃបាយថ្ងៃត្រង់ និងបើកជារៀងរាល់ថ្ងៃ។
- ភាគីនិយោជកបញ្ជាក់ថា មិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
    ០ និយោជកមិនមានលទ្ធភាពក្នុងការផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ចំនួន ៤០០០រៀល ដោយបើកជារៀងរាល់ថ្ងៃ ជូនកម្មករនិយោជិតនោះទេ ដោយហេតុថា បច្ចុប្បន្ននេះ ការបញ្ជាទិញថយចុះយ៉ាងខ្លាំង។
    ០ លើសពីនេះទៀត និយោជកបានផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ជូនកម្មករនិយោជិតចំនួន ១៥០០ រៀល ក្នុងមួយថ្ងៃ ដែលការផ្តល់ជូននេះ គឺជាអត្ថប្រយោជន៍បន្ថែមប្រសើរជាងច្បាប់កំណត់។
- ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលនូវឯកសារភស្តុតាង ៖ *"សេចក្តីប្រកាសជូនដំណឹង ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ៖ ក្រោយពីមានការប្រជុំ និងពិភាក្សាគ្នារវាងថ្នាក់ដឹកនាំក្រុមហ៊ុន និងប្រធានរោងចក្រ ក្រុមហ៊ុនសម្រេច និងឯកភាពផ្តល់ជូនលុយបាយដល់កម្មករនិយោជិត ដែលមានចែងដូចខាងក្រោម៖*

    *១- ក្រុមហ៊ុនសម្រេចនិងអនុញ្ញាតអោយកម្មករនិយោជិត ទាំងអស់ដែលធ្វើការ ពីម៉ោង 07:00-16:00នាទី ទទួលបានលុយបាយចំនួន ១៥០០៛។*

    *...*

    *- បើកលុយបាយមួយសប្តាហ៍ម្តងរៀងរាល់ថ្ងៃសៅរ៍អាទិត្យបន្ទាប់*

    *...*

    *យោងតាមការកំណត់ខាងលើនេះ ក្រុមហ៊ុននិងចាប់អនុវត្តន៍ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ នេះតទៅ ។...”*

**ហេតុផលនៃសេចក្តីសម្រេច ÷**

**ចំណុចវិវាទទី៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់អាហារថ្ងៃត្រង់មួយពេល ឬអាចផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ជូនកម្មករនិយោជិតដោយបើកជារៀងរាល់ថ្ងៃ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់អាហារថ្ងៃត្រង់មួយពេល ឬផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ដោយបើកជារៀងរាល់ថ្ងៃ ជូនកម្មករនិយោជិតដែរ ឬទេ ?

ផ្អែកតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា ការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ជូនកម្មករនិយោជិតចំនួន ១៥០០រៀល ក្នុងមួយថ្ងៃ និងបើកជូនកម្មករនិយោជិតរៀងរាល់មួយសប្តាហ៍ម្តងនៅថ្ងៃសៅរ៍។ បន្ថែមលើសពីនេះទៀត ផ្អែកតាមឯកសារ ភស្តុតាងរបស់ភាគីនិយោជកបានដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលអំពីសេចក្តីប្រកាសជូនដំណឹង ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២ ក៏បានបញ្ជាក់អំពីការផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ជូនកម្មករនិយោជិតចំនួន ១៥០០រៀល ក្នុងមួយថ្ងៃ និងបើករៀងរាល់មួយសប្តាហ៍ម្តងផងដែរ។

ក្នុងករណីនេះ ក្រៅពីអំណះអំណាងដែលភាគីទាំងពីរបានទទួលស្គាល់ខាងលើ មិនមានបទប្បញ្ញត្តិច្បាប់ស្តីពីការងារ បទបញ្ជា អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬការអនុវត្តកន្លងមក ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់អាហារថ្ងៃត្រង់មួយពេល ឬផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ដោយបើកជារៀងរាល់ថ្ងៃជូនកម្មករនិយោជិតនោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការទាមទាររបស់ភាគីកម្មករនិយោជិតក្នុងចំណុចវិវាទនេះ គឺជាការទាមទារអត្ថប្រយោជន៍បន្ថែមដែលមិនមានក្នុងបទប្បញ្ញត្តិច្បាប់ បទបញ្ជា អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ ឬបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។ ហេតុនេះ ចំណុចវិវាទនេះ គឺជាវិវាទអំពីផលប្រយោជន៍។

កថាខណ្ឌទី២ មាត្រា ៩៦ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "*២-អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងមាត្រា ៩៦ កថាខណ្ឌទី១ អនុសញ្ញារួមត្រូវធ្វើឡើងដោយព្រមព្រៀងគ្នារវាង ៖*

*ក- មួយចំណែក គឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយ ឬអង្គការច្រើនតំណាងឱ្យនិយោជក។*

*ខ- មួយចំណែកទៀត គឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត...*"។

យោងតាមកថាខណ្ឌទី២ មាត្រា ៩៦ នៃច្បាប់ស្តីពីការងារខាងលើ អនុសញ្ញារួមសំដៅលើកិច្ច-ព្រមព្រៀងជាលាយល័ក្ខណ៍អក្សរ ដែលធ្វើឡើងដោយព្រមព្រៀងគ្នារវាងនិយោជក ឬអង្គការនិយោជក និងអង្គការសហជីពដែលតំណាងឱ្យកម្មករនិយោជិត។

មាត្រា ៥៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា១៧ មាត្រា២០ មាត្រា២១ មាត្រា២៧ មាត្រា២៨ មាត្រា២៩ មាត្រា៥៤ មាត្រា៥៥ និងមាត្រា៥៩ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ (តទៅនេះហៅថាមាត្រា ៥៤ថ្មី នៃច្បាប់ស្តីពីសហជីព) ចែងថា ៖ "*ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។*

*សហជីពមួយនឹងទទួលបានភាពជាតំណាងបំផុត លុះត្រាតែសហជីពនោះបានបំពេញគ្រប់លក្ខណ-វិនិច្ឆ័យ ដូចតទៅ ៖*

*...*

*គ- មានបញ្ជីសមាជិកដែលបានកាត់ប្រាក់ភាគទានច្រើនជាងគេ ឬទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយដូចករណីខាងក្រោម ៖*

*- សហជីពដែលមានសមាជិក ចាប់ពី៣០%(សាមសិបភាគរយ)នៃចំនួនកម្មករ និយោជិតសរុបនៅក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពតែមួយ ឬ*

*- សហជីពណាដែលស្វែងរកបានការគាំទ្រពីសហជីពដទៃច្រើនជាងគេបំផុតដោយលើសពី៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថានដែលមានសហជីពលើសពី១(មួយ) ឬ*

*- ក្នុងករណីសហជីពណាមួយពុំអាចរកសមាជិកគាំទ្របាន ចាប់ពី៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុប ត្រូវរៀបចំការបោះឆ្នោតស្វែងរកការគាំទ្រឱ្យបានសំឡេងច្រើនជាងគេបំផុតលើសពី៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស ឬគ្រឹះស្ថាននោះ។...*

THE ARBITRATION COUNCIL

*ប្រសិនបើនៅក្នុងសហគ្រាស ឬគ្រឹះស្ថានមួយមានសហជីពមូលដ្ឋានច្រើនផ្សេងៗគ្នា មិនអាចបំពេញគ្រប់លក្ខណវិនិច្ឆ័យដូចមានចែងក្នុងកថាខណ្ឌខាងលើនៃមាត្រានេះ ហើយពុំអាចស្វែងរកការទទួលស្គាល់ភាពជាតំណាងបំផុតទេ ការចរចាចុះអនុសញ្ញារួមត្រូវតែអនុវត្តដាច់ខាតតាមមាត្រា ៧២(ក្រុមប្រឹក្សាចរចា)នៃច្បាប់នេះ។"*

មាត្រា ៧២ នៃច្បាប់ស្តីពីសហជីព ឆ្នាំ២០១៦ ចែងថា ៖ *"ក្រុមប្រឹក្សាចរចានៃសហជីព និងនិយោជក ដែលត្រូវបានបង្កើតឡើង មានសិទ្ធិពេញលេញក្នុងនាមកម្មករនិយោជិតទាំងអស់ ឬនិយោជកទាំងអស់នៅគ្រប់កម្រិតថ្នាក់ចរចាក្នុងករណីដែលត្រូវមានការចរចាចុះអនុសញ្ញារួមរវាងនិយោជកមួយ និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត ឬរវាងនិយោជកច្រើន និងសហជីពច្រើនដែលគ្មានភាពជាតំណាងបំផុត។"*

យោងតាមមាត្រា ៥៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព និងមាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើភាពជាតំណាងបំផុតរបស់សហជីពដែលជាភាគីវិវាទ ឬលក្ខណៈសម្បត្តិរបស់សហជីព ដែលជាភាគីវិវាទក្នុងនាមជាក្រុមប្រឹក្សាចរចា ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីព ឬលក្ខណៈសម្បត្តិរបស់សហជីពក្នុងនាមជាក្រុមប្រឹក្សាចរចា ផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីព ក្នុងការចរចាបង្កើតអនុសញ្ញារួមនៅក្នុងក្រុមហ៊ុន។

កថាខណ្ឌទី១ ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចែងថា ៖ *"សេចក្តីបង្គាប់អាជ្ញាកណ្តាលដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ។"*

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ ប្រការ ៤៣ នៃប្រកាស ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍នឹងក្លាយជាអនុសញ្ញារួមដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់បាត់បង់សិទ្ធិក្នុងការចរចាអនុសញ្ញារួម និងសិទ្ធិក្នុងការធ្វើកូដកម្ម ដើម្បីទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារ គឺជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាសដែលមានសិទ្ធិក្នុងការចរចាចុះអនុសញ្ញារួមស្របតាមមាត្រា ៥៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីសហជីព ឬសហជីពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមមាត្រា ៧២ នៃច្បាប់ស្តីពីសហជីពខាងលើ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ មិនពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិតនោះទេ ក្នុងករណីកម្មករនិយោជិតដែលជាភាគីដើមបណ្តឹង មិនមែនជាសហជីពដែលមានភាពជាតំណាងបំផុត ឬជាសហជីពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីសហជីព។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១៨/១៦-អ៊ី-ចេង (ខេមបូឌា) ខបកើរសិន ហេតុផលនៃចំណុចវិវាទទី៧, លេខ ២០៣/១៦-អ៊ិនយ៉ុង វ៉ុនដាង អ៊ីកែរីល ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៥, លេខ ០..../១៩-ខេមបូឌាន ថេកស្តាយ វើលវ៉ាយដ៍ ភ្នំពេញ វើក ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី៧, លេខ ០៦០/២០-ស្តារឡៃថ៍ អ៊ីកែរីល មេនូហ្វេកធីរីង ហេតុផលនៃចំណុចវិវាទទី២, លេខ ០៣៥/២១-ជេអេស ...)*

*សិន ហេតុផលនៃចំណុចវិវាទទី៣, និងលេខ ០៣៨/២១-ថៃប៊ុនរ៉ុង អ៊ិនដាសស្ទ្រី (ស៊ីខេ) ហេតុផលនៃចំណុចវិវាទទី២)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ភាគីដើមបណ្តឹងមិនមែនជាសហជីពដែលមានភាពជាតំណាងបំផុត ឬជាសហជីពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីសហជីព ក្នុងការដោះស្រាយវិវាទទាក់ទងនឹងផលប្រយោជន៍នោះឡើយ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើការទាមទាររបស់ភាគីកម្មករនិយោជិតទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់អាហារថ្ងៃត្រង់មួយពេល ឬផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ជូនកម្មករនិយោជិតដោយបើកជារៀងរាល់ថ្ងៃ។

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី៣ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់អាហារថ្ងៃត្រង់មួយពេល ឬផ្តល់ជាប្រាក់ចំនួន ៤០០០រៀល ជូនកម្មករនិយោជិតដោយបើកជារៀងរាល់ថ្ងៃ។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------